# របៀបឱ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក

July 2010

Khmer/ខ្មែរ

នៅថ្ងៃបោះឆ្នោត លោកអ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក: សន្លឹកឆ្នោតពណ៌បៃតងគឺសំរាប់សភាតំណាងរាស្ត្រ ហើយនិងសន្លឹកឆ្នោតពណ៌សគឺសំរាប់ព្រឹទ្ធសភា។

**សូមកុំខ្វល់ព្រួយអ្វីឡើយ ប្រសិនបើលោកអ្នកបានបំពេញខុស។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។**

## សន្លឹកឆ្នោតពណ៌បៃតង

### សូមសរសេរដាក់លេខគ្រប់ទាំងប្រអប់នីមួយៗ

ចំពោះសន្លឹកឆ្នោតពណ៌បៃតង លោកអ្នកនឹងត្រូវសរសេរដាក់លេខ ‘1’ នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជម្រើសទី១របស់លោកអ្នក។ រួចមកសរសេរដាក់លេខ ‘2’ នៅក្នុងប្រអប់ក្បែរជម្រើសទី២របស់លោកអ្នក ហើយជាបន្តបន្ទាប់មករហូតទាល់តែលោកអ្នកបានសរសេរដាក់លេខគ្រប់ប្រអប់នីមួយៗ។

**លោកអ្នកត្រូវតែសរសេរដាក់លេខឱ្យបានគ្រប់ទាំងប្រអប់ ដើម្បីឱ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក។**

សូមកុំប្រើសញ្ញាធីក (✓) សញ្ញាជើងក្អែក ឬទុកប្រអប់ចោលដោយមិនបានសរសេរដាក់លេខនៅពីលើសន្លឹកឆ្នោតនេះឲ្យសោះ បើមិនដូច្នោះទេនោះ គេនឹងពុំរាប់សន្លឹកឆ្នោតរបស់លោកអ្នកឡើយ។




គំរូ

សូមបើកទៅទំព័រម្ខាងទៀត ➡

# សន្លឹកឆ្នោតពណ៌ស

## វិធីពីរបែបដើម្បីបោះឆ្នោត

ចំពោះសន្លឹកឆ្នោតពណ៌ស លោកអ្នកមានជម្រើសពីរបែបដើម្បីបោះឆ្នោត៖

**មួយណាក៏បាន**

## ពីលើខ្សែបន្ទាត់

លោកអ្នកអាចគ្រាន់តែសរសេរដាក់លេខ ‘1’ នៅក្នុងប្រអប់ពីលើខ្សែបន្ទាត់សំរាប់គណៈបក្ស ឬក្រុមណាមួយនៃជម្រើសរបស់លោកអ្នកប៉ុណ្ណោះ។ តាមការធ្វើបែបនេះ លោកអ្នកអនុញ្ញាតឲ្យលំដាប់នៃការចូលចិត្តរបស់លោកអ្នក ត្រូវបានកំណត់ដោយគណៈបក្ស ឬក្រុមដែលលោកអ្នកបោះឆ្នោតឲ្យ។ ចំពោះពត៌មានបន្ថែម សូមបើកមើលវិបសាយ www.aec.gov.au




គំរូ

**ឬ**

## នៅក្រោមខ្សែបន្ទាត់

លោកអ្នកអាចជ្រើសរើសបំពេញប្រអប់នីមួយៗនៅក្រោមខ្សែបន្ទាត់ ទៅតាមលំដាប់នៃការចូលចិត្តរបស់លោកអ្នក។ លោកអ្នកត្រូវតែសរសេរដាក់លេខ ‘1’ នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជម្រើសទី១របស់លោកអ្នក។ រួចមកសរសេរដាក់លេខ ‘2’ នៅក្នុងប្រអប់ក្បែរជម្រើសទី២របស់លោកអ្នក ហើយជាបន្តបន្ទាប់មករហូតទាល់តែលោកអ្នកបានសរសេរដាក់លេខគ្រប់ប្រអប់នីមួយៗ។

**លោកអ្នកត្រូវតែសរសេរដាក់លេខឱ្យបានគ្រប់នាំងប្រអប់ ដើម្បីឱ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក។**




គំរូ